ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ២៣៩៣ ព.ណ. សហអ

ភ្នំពេញ, ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១

## ជម្រាបជូន

## ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាប្រធានភ្នាក់ងារអនុវត្តទាំង១៦ នៃគម្រោងកម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម

**កម្មវត្ថុ** : សំណើសុំចាត់បញ្ជូនមន្ត្រីចំនួនពីររូប ចូលរួមនៅក្នុងកិច្ចប្រជុំប្រចាំខែ មិថុនា ២០១១

**យោង** : លិខិតលេខ: ១១៥ សហអ របស់ DICO ចុះថ្ងៃទី ២១ មេសា ២០១១

**ភ្ជាប់ជូន** : របៀបវារៈនៃកិច្ចប្រជុំ និងឯកសារសម្រាប់កិច្ចប្រជុំ

តបតាមកម្មវត្ថុខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាតំណាងភ្នាក់ងារអនុវត្តគម្រោងកម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម (TDSP) មេត្តាជ្រាបថា: ដើម្បីជំរុញការអនុវត្តន៍គម្រោងឲ្យមានប្រសិទ្ធភាព និងមានភាពរលូន នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ (DICO) រៀបចំកិច្ចប្រជុំប្រចាំខែ មិថុនា រវាង DICO និង ភ្នាក់ងារអនុវត្តគម្រោង IAs (Implementing Agencies) ទាំងអស់ ក្នុងគោលបំណងស្វែងយល់អំពីការប្រឈម, ការងាយស្រួល, និងពិនិត្យពីវឌ្ឍនៈភាពនៃការ អនុវត្តន៍គម្រោង TDSP កន្លងមក។ សូមបញ្ជាក់ថា៖ ភ្នាក់ងារអនុវត្តត្រូវបំពេញក្នុងទម្រង់របាយការណ៍ប្រចាំខែឱ្យហើយស្រេច ។

ដើម្បីធានានូវការអនុវត្តន៍គម្រោងមានប្រសិទ្ធភាពខ្ពស់ប្រកបដោយតម្លាភាព និងបានទាន់ពេលវេលា ខ្ញុំសូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាប្រធានភ្នាក់ងារអនុវត្តគម្រោង មេត្តាចាត់បញ្ជូនមន្ត្រីជាថ្នាក់ដឹកនាំ និងមន្ត្រីបង្គោលមកចូលរួមក្នុងកិច្ចប្រជុំខាងលើ ដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ វេលាម៉ោង០៨:៣០ ព្រឹក នៅសាលប្រជុំនៃក្រសួងពាណិជ្ជកម្ម ។

សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

រដ្ឋលេខាធិការ

ចែម សុខឈៀង

ចម្លងជូន:
- ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
- ឯកឧត្តម ចាន់ សូរស័ក្តិ រដ្ឋលេខាធិការ
- ឯកឧត្តម ខិត ទីណា អនុរដ្ឋលេខាធិការ
- ឯកឧត្តម សុខ សុភ័ក្រ្ត អគ្គនាយកពាណិជ្ជកម្ម
- ឯកសារ កាលប្បវត្តិ

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣ប) ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469